ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៧១៧
ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ: ៥១៦
ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ: ៣៤៧
ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ៖ ៧៩ "ក"**
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺ។
កាលបរិច្ឆេទបើកសវនាការ៖ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ វេលាព្រឹក ។
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ វេលាព្រឹក ។

## ដោយមានសមាសភាពដូចតទៅ

### ក្រុមប្រឹក្សាជំនុំជម្រះ

-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាសមាជិក
-លោក [redacted] ជាសមាជិក

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧១៧ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖**

១-ឈ្មោះ [redacted] **សុខ** ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ មានទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] អៀត "ស" ម្ដាយឈ្មោះ [redacted] គុណ "រ" ប្រពន្ធឈ្មោះ គាំ ផង់ "រ" មានកូន០៤នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ (ក្រៅឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥០០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ។

-ដោះលែងតាមដីកាបង្គាប់ឱ្យដោះលែងលេខ ៩៩ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ។

<u>ជាប់ចោទពីបទ</u>: លួច ប្រព្រឹត្តនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

អមដោយលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខ ។

២-ឈ្មោះ [redacted] **ហ៊ីរិច** ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី១០ មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិជាំ ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ប៉ោង "រ" ម្ដាយឈ្មោះ [redacted] ហ៊ឺ "រ" ប្រពន្ធឈ្មោះ [redacted] សុម៉ាលី "រ" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

-មិនឃុំខ្លួនតាមដីកាសម្រេចមិនឃុំខ្លួនលេខ ២៥៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ។

<u>ជាប់ចោទពីបទ</u>: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ កថាខណ្ឌទី១ និង មាត្រា ៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

អមដោយលោក[redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ប៊ិាប ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ហ៊ុយ ភេទប្រុស កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៣ និង០០នាទីទាបភ្លឺ ស្ថិតនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជនជាប់ចោទឈ្មោះ[redacted] សុខ បានធ្វើសកម្មភាពលួចទាក់គោញីចំនួន ០១ក្បាល របស់ជនរងគ្រោះឈ្មោះ[redacted]ហ៊ុយ ភេទប្រុស អាយុ២៦ឆ្នាំ។ ក្រោយពេលលួចគោបានហើយ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ[redacted]សុខ បានយកគោនោះលក់ទៅឱ្យឈ្មោះ[redacted] ប៊ិាប ក្នុងតម្លៃចំនួន ២,៥០០,០០០(ពីរលានហាសិបម៉ឺន) រៀល នៅភូមិកើតហេតុខាងលើ ដោយពុំមានធ្វើលិខិតស្នាមអ្វីនោះទេ។ កន្លងមកឈ្មោះ[redacted] ប៊ិាប ធ្លាប់ទិញគោពីឈ្មោះ[redacted] សុខ ចំនួន០១ដង ហើយក៏ពុំមានលិខិតស្នាមអ្វីដែរ។

## <u>នាពេលសវនាការ</u>

**-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ**[redacted]សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖ ខ្លួនអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីនោះទេ។ ខ្លួនបានដឹងពីការចោទប្រកាន់របស់តំណាងអយ្យការរួចហើយ ។ ខ្លួនពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការពិតមែន ។

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១០ព្រឹក ខ្លួនបានយកកូនគោញីចំនួន០១ក្បាល សម្បុរចំប៉ា មានអាយុប្រហែល១៨ខែ លក់ឱ្យឈ្មោះ[redacted] ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅចំណុចភូមិជាំ ឃុំតាសាល ស្រុកឱរ៉ាល់ ក្នុងតម្លៃ ២,៥០០,០០០៛ (ពីរលានហាសិបម៉ឺន) រៀល ដោយមិនបានធ្វើលិខិតស្នាមអ្វីនោះទេ។ គោនោះជាគោរបស់ខ្លួនដែលកើតចេញពីមេគោរបស់ខ្លួនមានពណ៌ស ដែលបានលក់ឱ្យឈ្មោះ អាន ភេទប្រុស កាលពីខែតុលា ឆ្នាំ ២០២០។ ខ្លួនចំណាំគោលក់នោះ ក្រៅពីរូបរាងនៅចំណាំកន្ទុយចុងខ្មៅ (កន្ទុយពស់) អត់ស្នែង ស្នាក្របី (អត់បួក) ទៀត។ គោដែលបានលក់នោះ លើកដាក់ឡានកូរ៉េ នៅម៉ោងប្រហែលជា៩ព្រឹក។ ខ្លួនអាចចំណាំគោនោះបានដោយសាររូបខ្លួនតាមមើលគោនោះរហូតតាំងពីតូចមក មូលហេតុដែលលក់គោនោះដោយសារ ថាមេរបស់វាបានលក់ហើយវាមិនមានមេដើរតាមដូចគោរបស់ខ្លួនផ្សេងទៀតនោះទេពេលដែលចាប់គោលក់មិនមានអ្នកណាទៅជិទាស់នោះទេ ដោយបានចាប់ម៉ោងប្រហែល៣ទាបភ្លឺ ដោយសារពេលថ្ងៃចាប់មិនបានវារត់។ ពេលដែលខ្លួនលក់គោឱ្យទៅឈ្មោះ អាន ដែលជាមេរបស់គោដែលខ្លួនលក់ឱ្យឈ្មោះ ប៊ិាប គោនោះមានកូន០២ខែហើយក្នុងពោះ ។ គោរបស់ខ្លួនទាំងអស់ ប្រលែងវាចោលទៅរស់ក្នុងព្រៃទាំងអស់ ហើយអ្នកភូមិក៏ប្រលែងចោលដូចគ្នានៅរដូវប្រាំង។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា៨ព្រឹក ឈ្មោះ ហ៊ុយ ភេទប្រុស បានទៅតវ៉ានៅផ្ទះរបស់ខ្លួន ថាខ្លួនបានចាប់គោលក់ច្រឡំហើយ គោនោះជាគោរបស់ខ្លួន ។ ខ្លួនតបថាវិញថា មិនច្រឡំទេ ហើយពេលនោះបានជជែកគ្នាមិនត្រូវ បានដើរចេញរាងខ្លួន ។ លុះដល់ម៉ោងប្រហែល ៤រសៀល ថ្ងៃដដែល ឈ្មោះ ហ៊ុយ បានទៅដាក់ពាក្យបណ្តឹងនៅអធិការស្រុកឱរ៉ាល់ ហើយនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ម៉ោងប្រហែលជា៩ព្រឹក សមត្ថកិច្ចបានហៅ

ខ្លួនទៅសាកសួរនាំនៅអធិការស្រុកឱរ៉ាល់ ហើយបាន់ឃាត់ខ្លួនតែម្តង។ ឈ្មោះ ហ៊ុយ បានដឹងដំណឹងថាគោនោះ ខ្លួនបានលក់ដោយសារតែអ្នកភូមិប្រាប់តគ្នាថាខ្លួនបានលក់ឱ្យគេ ហើយពេលដែលឈ្មោះ ហ៊ុយ ដើររក។ ខ្លួនក្រៅពីចំណាំគោ នៅមានអ្នកភូមិស្គាល់គោនោះផងដែរមានឈ្មោះ ភ័ក្រ្ត និងអ្នកផ្សេងទៀត ខ្លួន និងដាក់ឈ្មោះសាក្សី តាមក្រោយ ។ ខ្លួនធ្លាប់បានលក់គោឱ្យឈ្មោះ ប៊ាប បានចំនួន២ដងហើយ លើកទី១ លក់គោចំនួន២ក្បាល បានតម្លៃ ៤,៤០០ ,០០០ (បួនលានបួនសែន)រៀល ជាគោរបស់ខ្លួនចិញ្ចឹមដែរ ។ ខ្លួនមិនមែនជាអ្នករកស៊ីលក់គោអីនោះទេ ហើយលក់គោនៅពេលដែលវាធំល្មមលក់ដោយសារមានគោច្រើន។ រាល់ថ្ងៃខ្លួននៅសល់គោចំនួន០៨ក្បាលទៀត។ កាលពីមុនមិនដែលមានរឿងឈ្លោះប្រកែកគ្នាជាមួយឈ្មោះ ហ៊ុយ នោះទេ ។ ឈ្មោះ ហ៊ុយ ជាអ្នករស់នៅភូមិជាមួយខ្លួន ចំងាយប្រហែល ៨០០ម៉ែត្រពីគ្នា។ ពេលចាប់គោទៅម្នាក់ឯង ដោយទាក់ករវា ហើយពេលចាប់បានហើយអ្នកទិញលើកដាក់ឡានកូរ៉េ ។ ឈ្មោះ ប៊ាប ជាអ្នករកស៊ីកាប់គោ ហើយតែងតែដើរទិញគោអ្នកភូមិ។ ពេលដែលលក់គោ បានប្រាប់ឈ្មោះ ប៊ាប ថាខ្លួនចង់លក់គោមួយក្បាល ហើយគាត់ប្រាប់ថាព្រមទិញយក។ ចំពោះគោញីជាទូទៅ១ឆ្នាំ ឬអាចលើសតិចតួច មានកូនម្តង ។ ចំពោះគោដែលបានលក់ហើយមានទំនាស់នោះ អធិការស្រុកបានប្រគល់ឱ្យឈ្មោះ ហ៊ុយ វិញហើយ ។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតទូរស័ព្ទចំនួន០១គ្រឿង ម៉ាក វីវ៉ូ ចាស់ ។

**-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ខ្លួនអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីនោះទេ ។ ខ្លួនបានដឹងពីការចោទប្រកាន់របស់តំណាងអយ្យការរួចហើយ។ ខ្លួនពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការពិតមែន ។

កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង១០ព្រឹក ខ្លួនកំពុងនៅផ្ទះស្ថិតនៅភូមិជាំ ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ស្រាប់តែឈ្មោះ[redacted]សុខ ភេទប្រុស អាយុ៤០ឆ្នាំ មានទីលំនៅភូមិថ្មី ឃុំតាសាល ស្រុលឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានទាក់ទង ទូរស័ព្ទមកខ្លួនថា គាត់មានមេគោចំនួន ០១ក្បាល សម្រាប់លក់ ហើយខ្លួនបានតបទៅគាត់វិញថាចាំបន្តិចទៀត ចាំខ្លួនទៅមើលនៅផ្ទះបង ។ លុះដល់វេលាម៉ោងប្រហែល១០ និង៣០នាទីព្រឹក ថ្ងៃដដែល ខ្លួនបានជិះឡានទៅដល់ផ្ទះរបស់ឈ្មោះ [redacted]សុខ ដើម្បីមើលគោ ដោយពេលទៅដល់ឈ្មោះ [redacted]សុខ បានចង្អុលប្រាប់ខ្លួនថាគាត់ចង់លក់មេគោរបស់គាត់មួយនេះ ដែលចងនៅមុខផ្ទះរបស់អ្នកជិតខាងគាត់ក្នុងតម្លៃ២,៥០០,០០០៛ (ពីរលានហាសិបម៉ឺន) រៀលឱ្យទៅឈ្មោះ [redacted] សុខ រួចបើកឡានដឹកគោត្រឡប់មកផ្ទះខ្លួនវិញ ។ ស្រាប់តែថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង៧ព្រឹក ក៏មានឈ្មោះ [redacted] ហ៊ុយ ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ មានទីលំនៅនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានមកផ្ទះរបស់ខ្លួន និងបានសុំទៅចូលមើលគោដែលខ្លួនបានទិញពីឈ្មោះ [redacted] សុខ ហើយខ្លួនក៏បានយល់ព្រម រួចឈ្មោះ [redacted] ហ៊ុយ បានអះអាងថា គោនោះជាគោរបស់គាត់ មិនមែនជាគោរបស់ឈ្មោះ [redacted] សុខ នោះទេ ដោយឈ្មោះ [redacted] សុខ ចាប់ច្រឡំហើយ។ រួចខ្លួនក៏បានតបវិញថាមិនអីទេប្អូនទៅដោះស្រាយគ្នាទៅ បងយកតែថ្លៃទិញគោវិញនោះទេ ហើយឈ្មោះ [redacted] ហ៊ុយ ក៏បានត្រឡប់ទៅវិញ ។ លុះល្ងាចឡើងប៉ូលីសខាងអធិការដ្ឋាននគរបាលស្រុកឱរ៉ាល់ បានមកហៅខ្លួននៅផ្ទះឱ្យទៅដោះស្រាយរឿងគោនៅប៉ុស្តិ៍នគរបាលឃុំតាសាល ហើយខ្លួនក៏បានទៅ ។ នៅពេលទៅដល់ឃើញឈ្មោះ [redacted] សុខ និងឈ្មោះ [redacted]ហ៊ុយ កំពុងត្រូវសមត្ថកិច្ចសាកសួរ ថាតើអ្នកណាជាម្ចាស់គោ ហើយនៅតែមិនអាចបែងចែកបាន ដោយពេលល្ងាចហើយសមត្ថកិច្ចក៏បានឱ្យភាគីទាំងអស់ត្រឡប់ទៅផ្ទះវិញ និងណាត់ឱ្យទៅអធិការដ្ឋានស្រុកឱរ៉ាល់នៅពេលព្រឹកឡើង ។ លុះព្រឹកឡើងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ នៅពេលទៅដល់អធិការដ្ឋាននគរបាលស្រុកឱរ៉ាល់ សមត្ថកិច្ចបានសាកសួរខ្លួន ឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហ៊ុយ ម្តងម្នាក់ ហើយខ្លួនបានឆ្លើយតាមសាច់រឿង ដែលខ្លួនបានឆ្លើយខាងលើជូនសមត្ថកិច្ច ពេលដែលសមត្ថកិច្ចសាកសួររួច បានឱ្យខ្លួនផ្តិតមេដៃ

ប្រគល់គោឱ្យឈ្មោះ [redacted] ហ៊ុយ វិញ រួចសមត្ថកិច្ចក៏បានឱ្យខ្លួនត្រឡប់មកផ្ទះវិញ រីឯឈ្មោះ [redacted] សុខ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ លុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៦និង៣០នាទីព្រឹក ខ្លួនក៏បានដឹក មេគោ នោះយកទៅឱ្យឈ្មោះ [redacted] ហ៊ុយ វិញ នៅផ្ទះរបស់គាត់ ដោយមានមេភូមិដឹងលឺជាសាក្សី រួចខ្លួនក៏បានបើកឡានត្រឡប់មកផ្ទះវិញ នៅពេលដែលខ្លួនទៅទិញគោពីឈ្មោះ [redacted] សុខ នោះគឺឈ្មោះ [redacted] សុខ បានអះអាងថាជាគោរបស់គាត់ ហើយខ្លួនក៏មិនដឹងថាគោនោះ មានការចាប់ខុស ឬចាប់ច្រឡំគោរបស់ឈ្មោះ [redacted] ហ៊ុយ ដែរ។ លុះថ្ងៃទី២១ ទើបឈ្មោះ [redacted] ហ៊ុយ ទៅសុំមើលគោ ទើបខ្លួនដឹងរឿង ។ នៅពេលខ្លួនទិញគោពីឈ្មោះ [redacted] សុខ គឺមិនបានធ្វើកិច្ចសន្យាអ្វីនោះទេ ដោយយល់ថាជាអ្នកស្គាល់គ្នា និងរស់នៅជិតគ្នា ។ កន្លងមកនៅក្នុងឆ្នាំ២០២១ នេះ ខ្លួនធ្លាប់ទៅទិញគោពីឈ្មោះ [redacted] សុខ បានចំនួន ០២ក្បាលដែរ គឺគោឈ្មោលមួយក្បាល និងគោញី មួយក្បាល ។ ហើយកន្លងមក ខ្លួនក៏ធ្លាប់ទិញគោពីអ្នកភូមិ ជាច្រើនដងមកហើយដែរ ព្រោះខ្លួនប្រកបរបរកាប់គោនេះ តែមិនដែលមានបញ្ហាអ្វីនោះទេ ទើបតែលើកទី១ ។ ចំពោះគោនៅ ផ្ទះរបស់ឈ្មោះ [redacted] សុខ បច្ចុប្បន្នមានចំនួនប្រហែល០៨ក្បាល ។ បានជាមានការយល់ច្រឡំបែបនេះ គឺដោយសារតំបន់នេះ នៅរដូវច្រូតកាត់រួចប្រជាពលរដ្ឋនៅទីនេះតែងតែលែងគោចូលព្រៃ ដោយពុំមានតាមមើលថែអ្វីទេ លុះដល់ចាប់គោយកមកវិញ គោប្លែកធ្វើឱ្យមានភាពភាន់ច្រឡំ ។ ហើយកន្លងមកអ្នកភូមិក៏ធ្លាប់មានបញ្ហាច្រឡំគោគ្នាដែរ តែគេដោះស្រាយគ្នាបញ្ចប់រឿង ។

**-តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ុយ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** មុនដំបូងខ្លួនបានទាក់គោចាក់កន្ទុះ ហើយគោនៅក្នុងក្រោលខ្លួនមានចំនួន០៧ (ញីចំនួន០៥ តូច០២) ចំណែកគោដែលត្រូវខ្ទុះមានចំនួន០៣ (ញី០២ក្បាល និងឈ្មោល០១ក្បាល) ។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ខ្លួនបានទាក់គោទាំងនោះខ្ទុះ ហើយពេលនោះទាក់បាន០៣ក្បាល រួចដាក់ខ្ទុះបានគោ០១ក្បាល(ឈ្មោល) ហើយគោ០១ក្បាលទៀត (ញី) បានរួច ដោយសារអត់ស្នែង និងរត់ចេញពីហ្វូងទៅ ចំណែកគោញី០១ក្បាលទៀត ឈឺជើងមិនហ៊ានដាក់ខ្ទុះខ្លាចវាអន់ស្មៅ ចំណែកគោដែលបាត់រួចនោះ បាននៅតាមហ្វូងនៅឡើយទេ តែគ្រាន់តែវាមិនចូលក្រោល ហើយខ្លួនក៏បានដេញទាក់វាទៀត តែទាក់មិនបាន វាក៏ចេញពីហ្វូងមកនៅផ្ទះឈ្មោះ ហាន ។ ខ្លួនធ្លាប់បានទៅមើល និងសួរប្រពន្ធឈ្មោះ ហាន ថាឃើញគោខ្លួននៅហ្នឹងអត់ គាត់ក៏ថានៅហ្នឹងទេ ។ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៦ និង៣០នាទីព្រឹក ខ្លួនក៏បានទៅសួរប្រពន្ធរបស់ ពូហាន ដូចរាល់ដង គាត់ប្រាប់ខ្លួនថា ឈ្មោះ [redacted] សុខ បានទាក់និងលក់ឱ្យដង្កៅគោឈ្មោះ [redacted] ប៊ិាប នៅផ្សារជាំបាត់ហើយ ។ លឺដូចនេះខ្លួនបានជិះម៉ូតូតែម្នាក់ឯងមកផ្ទះដង្កៅគោឈ្មោះ [redacted] ប៊ិាប ក៏ឃើញគោខ្លួននៅទីនោះមែន គឺសម្បុរសលាយក្បាលក្រហម (ចំប៉ា) រួចខ្លួនក៏សួរពូឈ្មោះ ប៊ិាប ថា ទិញគោនេះមកពីខាងណា គាត់ថាទិញមកពីឈ្មោះ [redacted] សុខ នៅភូមិថ្មី ហើយខ្លួនក៏ប្រាប់គាត់ថា គោនេះជាគោរបស់ខ្លួនទេ ពេលនោះពូឈ្មោះ [redacted] ប៊ិាប ប្រាប់ថា ទៅនិយាយជាមួយឈ្មោះ [redacted] សុខ ទៅចាំគាត់រក្សាគោនេះទុកឱ្យ ភ្លាមនោះខ្លួនក៏មកប្រាប់មេភូមិឱ្យគាត់ជួយដោះស្រាយឱ្យ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** គោដែលឈ្មោះ [redacted] សុខ បានចាប់លក់នោះ គឺជាគោរបស់ឈ្មោះ [redacted] សុខ ដោយខ្លួនស្គាល់គោនោះច្បាស់ វាជាគោញី សម្បុរសក្បាលក្រហម កន្ទុយឆ្នូតស ហើយគោនោះមានអាយុដល់ថ្ងៃចាប់លក់មានអាយុប្រហែលជា២-៣ឆ្នាំ ។ រូបខ្លួនដឹងថាឈ្មោះ [redacted] សុខ ទៅចាប់កូនគោញីនោះលក់ ដោយស្មារគាត់ទៅហៅប្ដីខ្លួនឈ្មោះ [redacted] អាត ឱ្យជួយចាប់ តែប្ដីខ្លួនអត់បានទៅដោយសាររវល់ ។ ចំពោះគោរបស់ឈ្មោះ [redacted] ហ៊ុយ រូបខ្លួនមិនដែលស្គាល់ ហើយមិនដឹងថាគាត់មានគោប៉ុន្មាននោះទេ ។ ឈ្មោះ សុខ មានគោចំនួន១១ក្បាល ហើយបានលក់អស់ចំនួន០៣ក្បាលហើយ ។ ឈ្មោះ [redacted] សុខ ជាមនុស្ស

ល្អនៅក្នុងភូមិ មានទំនាក់ទំនងល្អជាមួយញាតិមិត្ត ហើយមិនមែនជាចោរលួចគោគេនោះទេ ។ អ្នកភូមិនៅនោះ គឺប្រលែងគោចោលពេលរដូវប្រាំង ហើយចាប់មកវិញនៅរដូវវស្សា ។ គោពេលល្ងាចវាតែងតែដើរមកចូលភូមិវិញ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ឡាវ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ខ្លួនជាកូនរបស់ឈ្មោះ [redacted]សុខ ។ ឪពុករបស់ខ្លួនមានគោចំនួន១១ក្បាល តែលក់អស់០៣ក្បាលហើយ ។ គោដែលឪពុកខ្លួនលក់ចុងក្រោយនោះ គឺមិនចាំថ្ងៃ ក្នុងខែកក្កដា ឆ្នាំ២០២១ គោនោះជាគោញី មានសម្បុរស ក្រហម ក្បាលក្រហម និងខ្លួនសក្រចកមានឆ្នូតស កន្ទុយវែង ពណ៌ខ្មៅឆ្នូតស លក់ទៅឱ្យពូឈ្មោះ[redacted] ប៉ោប ក្នុងតម្លៃចំនួន ២,៥០០,០០០៛ (ពីរលានហាសិបម៉ឺន) រៀល ។ ខ្លួនស្គាល់គោនោះច្បាស់ ដោយសាររូបខ្លួនជាអ្នកឃ្វាលវា និងគោផ្សេងទៀត ។ ខ្លួនធ្លាប់ឃើញគោរបស់ឈ្មោះ [redacted] ហ៊ុយ មានពណ៌ក្រហមស ក្បាលក្រហម ខ្លួនពណ៌ស ទាប និងតូចជាងគោរបស់ខ្លួន ហើយជាគោឈ្មោល ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] អាត ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** រូបខ្លួនធ្លាប់បានសុំទិញគោឈ្មោះ [redacted] សុខ តែគាត់ព្រមលក់ឱ្យដោយសារថាខ្លួនមិនមានលុយគ្រប់ ។ ក្រោយពីមានចិត្តស្រលាញ់គោនោះ (ញី) រូបខ្លួនបានសម្គាល់គោនោះមានសម្បុរស លាយក្រហមក្បាល ក្បាលមានពណ៌ក្រហម (ផ្ដើមក្បាល) ក្រចកជើងឆ្នូតពណ៌សតិចៗទាំងបួន។ រូបខ្លួនមិនដឹងថាឈ្មោះ ងីន សុខ ចាប់គោញីនោះលក់នោះទេ ហើយក៏មិនដឹងថាគាត់លក់ឱ្យអ្នកណានោះដែរ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] សំអាន ភេទប្រុស អាយុ៦២ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** រូបខ្លួនបានឃើញឈ្មោះ[redacted] សុខ កំពុងរត់ ហើយខ្លួនបានស្រែកសួរថា ទៅណាកូនសុខ ហើយឈ្មោះ[redacted] សុខ បានឆ្លើយថា ខ្ញុំទៅចាប់គោ ។ ខ្លួនមិនដឹងថាឈ្មោះ[redacted] សុខ ទៅចាប់គោញី ឬ ឈ្មោល នោះទេ ហើយនៅទីណាដែរ។ រូបខ្លួនមិនដែលស្គាល់គោរបស់ឈ្មោះ[redacted] សុខ នោះទេ ចំណែកគោរបស់ឈ្មោះ [redacted] ហ៊ុយ ក៏ខ្លួនដែលស្គាល់ដែរ ។ ខ្លួនដឹងត្រឹមថាឈ្មោះ[redacted] សុខ ជាមនុស្សល្អនៅក្នុងភូមិ ហើយមិនមែនជាចោរលួចគោគេនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]មុំ ភេទស្រី អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** រូបខ្លួនមិនដែលស្គាល់គោរបស់ឈ្មោះ[redacted]សុខ នោះទេ ចំណែកគោរបស់ឈ្មោះ [redacted] ហ៊ុយ ក៏ខ្លួនពុំដែលស្គាល់ដែរ ។ ខ្លួនដឹងត្រឹមថាឈ្មោះ [redacted]សុខ ជាមនុស្សល្អនៅក្នុងភូមិ និងស្រលាញ់សាច់ញាតិ ហើយមិនមែនជាចោរលួចគោគេនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]មុំ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ថ្ងៃដែលឈ្មោះ [redacted] សុខ ចាប់គោនោះ គឺនៅវេលាម៉ោងប្រហែលជា៦.០០នាទីល្ងាច ខ្លួនបានសួរឈ្មោះ[redacted] សុខ ថា ទៅណា ឈ្មោះ [redacted] សុខ ឆ្លើយថា ទៅចាប់គោ ។ រូបខ្លួនមិនដែលស្គាល់គោរបស់ឈ្មោះ[redacted]សុខ នោះទេ ចំណែកគោរបស់ឈ្មោះ[redacted] ហ៊ុយ ក៏ខ្លួនដែលស្គាល់ដែរ ។ ខ្លួនដឹងត្រឹមថាឈ្មោះ[redacted]សុខ ជាមនុស្សល្អនៅក្នុងភូមិ និងស្រលាញ់សាច់ញាតិ ហើយមិនមែនជាចោរលួចគោគេនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] ណៃត ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ថ្ងៃដែលឈ្មោះ [redacted] សុខ ចាប់គោនោះ គឺនៅវេលាម៉ោងប្រហែលជា៦.០០ នាទីល្ងាច ខ្លួនបានសួរឈ្មោះ[redacted] សុខ ថា ទៅណា ឈ្មោះ[redacted]សុខ ឆ្លើយថា ទៅចាប់គោលក់នៅផ្ទះឈ្មោះ ភ័ក្ត្រ ។ រូបខ្លួនមិនដែលស្គាល់គោរបស់ឈ្មោះ ងីន សុខ នោះទេ ចំណែកគោរបស់ឈ្មោះ [redacted] ហ៊ុយ ក៏ខ្លួនដែលស្គាល់ដែរ ។ ខ្លួនដឹងត្រឹមថាឈ្មោះ[redacted] សុខ ជាមនុស្សល្អនៅក្នុងភូមិ និងស្រលាញ់សាច់ញាតិ ហើយមិនមែនជាចោរលួចគោគេនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted]**កេន ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ខ្លួនស្គាល់គោដែលឈ្មោះ [redacted] សុខ បានចាប់លក់នោះច្បាស់ ព្រោះជាគោរបស់ឈ្មោះ [redacted] សុខ ពិតមែន ។ គោនោះមានសម្បុរសលាយក្រហមក្បាល ក្បាលមានពណ៌ក្រហម (ផ្ដើមក្បាល) ជាគោញី ។ ឈ្មោះ [redacted] សុខ ចាប់កូនគោញីនោះលក់ឱ្យឈ្មោះ ភាព នៅដីចិន ។ ឈ្មោះ [redacted] សុខ មានគោច្រើន ប្រហែលជា០៩ក្បាល តែខ្លួនមិនស្គាល់ច្បាស់ទាំងអស់នោះទេ ។ ខ្លួនសូមអះអាងគោដែលឈ្មោះ [redacted] សុខ បានចាប់លក់នោះ ជាគោរបស់គាត់ មិនមែនជាគោរបស់ឈ្មោះ [redacted] ហ៊ុយ នោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted] **ផង់ ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ចំពោះគោដែលប្ដីរបស់ខ្លួនបានចាប់លក់ទៅឱ្យឈ្មោះ ប៊ាប គឺជាគោរបស់ខ្លួន ដោយខ្លួនចំណាំបានច្បាស់ត្រង់ក្រចកជើងសទ្ធតទាំងបួន លើក្បាលមានស្នាមក្រហមព្រឿងៗតិច កន្ទុយវារាងស ។ ប្ដីរបស់ខ្លួនទៅចាប់គោនោះនៅផ្ទះរបស់ឈ្មោះ [redacted] សុភ័ក្រ្ត រស់នៅភូមិជាមួយគ្នា ដោយទៅចាប់ពេលល្ងាចព្រលប់ៗ ទៅពីរនាក់កូនឈ្មោះ [redacted] ប៊ុនឡាយ ។ ពេលចាប់បានហើយ នៅម៉ោងប្រហែលជា៨.០០នាទីព្រឹក ទើបអ្នកទិញគោកាប់គោនោះឈ្មោះ ប៊ាប បានដឹកគោដាក់ឡានកូរ៉េ ។ ក្រៅពីខ្លួន ប្ដីខ្លួន និងកូនដែលស្គាល់គោនោះច្បាស់ នៅមានសាក្សីអ្នកជិតខាងផ្សេងទៀតដូចជាឈ្មោះ [redacted] សុភ័ក្រ្ត , ឈ្មោះ [redacted]ថាច, ឈ្មោះ [redacted] សុខា និងអ្នកផ្សេងទៀត សុទ្ធតែអាចបញ្ជាក់ថាគោដែលប្ដីខ្លួនបានលក់នោះ ជាគោរបស់ខ្លួន ។ គោរបស់ខ្លួនមានចំនួន០៥ក្បាល (លក់អស់០១ក្បាល) កូនចំនួន០៧ក្បាល (លក់អស់០៣ក្បាល) លក់ឱ្យឈ្មោះ ប៊ាប ទាំងអស់ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted]**សុខសាន្ត ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** កាលពីថ្ងៃទី១៨ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង៦.០០នាទីល្ងាច ពេលនោះខ្លួនបានជួបឈ្មោះ [redacted] សុខ នៅផ្ទះ [redacted] សុភ័ក្រ្ត កំពុងដើររកចាប់គោ ហើយបានសួរទៅឈ្មោះ [redacted] សុខ ថាធ្វើអី ឈ្មោះ [redacted] សុខ បានប្រាប់ថាចាប់គោលក់ ។ រូបខ្លួនមិនបានស្គាល់គោរបស់ឈ្មោះ [redacted] សុខ ឬគោអ្នកណានោះទេ ។ រូបខ្លួនមិនដឹងថាឈ្មោះ [redacted] សុខ មានគោប៉ុន្មានក្បាលនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted] **សុខុម ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** ខ្លួនមិនដឹងរឿងច្បាស់នោះទេ គ្រាន់តែថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៧ និង៣០នាទីព្រឹក មេភូមិថ្មីឈ្មោះ [redacted] ច្រេវ បានទូរស័ព្ទរាយការណ៍ប្រាប់ខ្លួនថា មានករណីលួចគោ ដោយមានបុរសម្នាក់លួចគោគេលក់ ហើយអះអាងថាគោរបស់គាត់ តែតាមពិតគោរបស់គាត់ គឺជាគោញីនោះទេ បន្ទាប់មក ខ្លួនក៏បានតបវិញថា ករណីនេះមិនមែនជាសមត្ថកិច្ចរបស់ខ្លួននោះទេ គឺជាសមត្ថកិច្ចរបស់នគរបាលប៉ុស្ដិ៍ និងអធិការស្រុក ហើយគាត់ក៏បានរាយការណ៍ទៅខាងសមត្ថកិច្ចនគរបាលវិញទៅ ។ ខ្លួនដឹងរឿងតែប៉ុននេះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted]**សុភ័ក្រ្ត ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖** កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា៨.០០នាទីយប់ ឈ្មោះ [redacted] សុខ រស់នៅភូមិជាមួយគ្នា បានទៅចាប់គោរបស់គាត់នៅផ្ទះរបស់ខ្លួន ។ គោនោះញី ពណ៌ស ក្បាលក្រហម អាយុប្រហែល១ខួបជាង ។ ឈ្មោះ [redacted] សុខ បានចាប់គោនោះដើម្បីលក់ ដោយសារខ្វះលុយបង់ធនាគារ ។ ខ្លួនស្គាល់យ៉ាងច្បាស់ថា គោដែលឈ្មោះ [redacted] សុខ បានចាប់លក់ឱ្យគេនោះ គឺជាគោរបស់គាត់ពិតមែន ។ ខ្លួនអះអាងថា គោនោះជាគោរបស់ឈ្មោះ [redacted] សុខ ដោយសារគោនោះតែងតែមកដេកនៅផ្ទះរបស់ខ្លួនតាំងពីតូច ហើយឃើញលើក្បាលវាមានស្នាមក្រហមព្រឿងៗ និងម្យ៉ាងទៀត កូនរបស់ខ្លួន និងកូនរបស់ឈ្មោះ [redacted] សុខ តែងតែទៅឃ្វាលគោជាមួយគ្នា ទើបខ្លួនស្គាល់គោនោះច្បាស់ ។ ក្រៅពីខ្លួនស្គាល់គោនោះ

មានអ្នកផ្សេងទៀតដែលស្គាល់គោនោះច្បាស់ដែរ មានឈ្មោះ [redacted] ថាច និងឈ្មោះ [redacted] សុខា ដែលមកធ្វើសាក្សីជាមួយគ្នា ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted] សុខា ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា៨.០០ នាទីយប់ ឈ្មោះ [redacted] សុខ រស់នៅភូមិជាមួយគ្នា បានទៅចាប់គោរបស់គាត់នៅផ្ទះរបស់ឈ្មោះអែម សុភ័ក្ត្រ ។ គោនោះញី ពណ៌ស ក្បាលក្រហមតិច អាយុប្រហែល១ខួបជាង ។ ឈ្មោះ [redacted] សុខ បានចាប់គោនោះដើម្បីលក់ ដោយសារខ្វះលុយបង់ធនាគារ ។ ខ្លួនស្គាល់យ៉ាងច្បាស់ថា គោដែលឈ្មោះ [redacted] សុខ បានចាប់លក់ឱ្យគេនោះ គឺជាគោរបស់គាត់ពិតមែន ដោយសារតែកាលពីខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] សុខ បានលក់មេគោរបស់គាត់០១ក្បាល មិនដឹងតម្លៃ មិនដឹងលក់ឱ្យអ្នកណានោះទេ ហើយពេលនោះខ្លួនឃើញកូនគោញីដែលឈ្មោះ [redacted] សុខ បានលក់នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ នោះ ខ្លួននៅទីនោះដែរ ព្រោះថាកូនរបស់គោញី ដែលឈ្មោះ [redacted] សុខ បានលក់កាលពីខែតុលា ឆ្នាំ២០២០ នោះ ធ្វើឱ្យខ្លួនចំណាំបាននៅលើក្បាលកូនគោញីនោះមានស្នាមក្រហមបន្តិចលើក្បាល។ ខ្លួនមិនដឹងថាឈ្មោះ [redacted] សុខ មានគោប៉ុន្មាននោះទេ ចំណែកឈ្មោះ [redacted] ហ៊ុយ ក៏មិនដឹងថាគាត់មានគោប៉ុន្មានដែរ ។ ខ្លួនដឹងថាកូនគោញីនោះ ជាកូនរបស់គោដែលឈ្មោះ [redacted] សុខ បានលក់កាលពីខែតុលា ឆ្នាំ២០២០ ព្រោះឈ្មោះ [redacted] សុខ បានប្រាប់ខ្លួន ។ ក្រៅពីខ្លួនស្គាល់គោនោះច្បាស់ មានអ្នកផ្សេងទៀតដែលស្គាល់ច្បាស់ដែរ មានឈ្មោះ [redacted] សុភ័ក្ត្រ និងឈ្មោះ គាំ ថាច ដែលមកធ្វើសាក្សីជាមួយគ្នា ។ ចំពោះឈ្មោះ [redacted] ហ៊ុយ ថាគោនោះជាគោរបស់គាត់ដែរ គឺមិនពិតនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted] ថាច ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា៦.០០នាទីយប់ ឈ្មោះ [redacted] សុខ រស់នៅភូមិជាមួយគ្នា បានទៅចាប់គោរបស់គាត់នៅផ្ទះរបស់ឈ្មោះ [redacted] សុភ័ក្ត្រ ។ គោនោះញី ពណ៌ស ក្បាលក្រហមតិច មិនដឹងអាយុនោះទេ ។ ឈ្មោះ [redacted] សុខ មានមេគោចំនួនប្រហែលជា០៥ក្បាល កូនមានច្រើនមិនដឹងប៉ុន្មាននោះទេ ចំណែកគោរបស់ឈ្មោះ [redacted] ហ៊ុយ ក៏មិនដឹងមានប៉ុន្មានដែរ ។ ខ្លួនអះអាងថា គោដែលឈ្មោះ [redacted] សុខ បានលក់នោះជាគោរបស់ឈ្មោះ [redacted] សុខ ដោយខ្លួនចំណាំក្បាលមានក្រហមល្មម ហើយខ្លួនឃើញថាជាកូនគោមេដែលឈ្មោះ [redacted] សុខ លក់កាលពីខែតុលា ឆ្នាំ២០២០ តាំងពីវានៅបៅមេវាម្ល៉េះ ។ ចំពោះឈ្មោះ [redacted] ហ៊ុយ ថាគោនោះជាគោរបស់គាត់ដែរ គឺមិនពិតនោះទេ ។

**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ** [redacted] សាន ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖ ខ្លួនមានតួនាទីជាអនុប្រធានភូមិថ្មី ខ្លួនមកបំភ្លឺជំនួសប្រធានភូមិថ្មី ដោយលោក [redacted] ច្រេវ គាត់ជួបគ្រោះថ្នាក់ចរាចរណ៍ ហើយកំពុងសម្រាកព្យាបាលនៅផ្ទះ ទើបមិនអាចធ្វើដំណើរមកកើត ។ ទាក់ទងនឹងករណីលួចគោ គឺបានកើតឡើងនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ នៅចំណុចភូមិថ្មី ឃុំតាសាល ស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ខ្លួនបានដឹងរឿងនេះនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទីព្រឹក ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ុយ បានមកផ្ទះរបស់ខ្លួន ហើយប្រាប់ខ្លួនថាឈ្មោះ [redacted] សុខ បានលួចទាក់គោរបស់គាត់ យកទៅលក់បាត់ហើយ ហើយឱ្យខ្លួនហៅឈ្មោះ [redacted] សុខ មកដោះស្រាយ ដើម្បីយកគោគាត់ត្រឡប់ទៅវិញ រួចខ្លួនក៏បានរាយការណ៍ទៅលោកមេភូមិថ្មី និងបានទៅហៅឈ្មោះ [redacted] សុខ ឱ្យទៅដោះស្រាយគ្នានៅសាលប្រជុំភូមិ ។ លុះវេលាម៉ោង០៩និង០០ នាទីព្រឹក នៅថ្ងៃដដែល ឈ្មោះ [redacted] ហ៊ុយ , ឈ្មោះ [redacted] សុខ , លោកប្រធានភូមិ និងរូបខ្លួនក៏បានជុំគ្នានៅសាលប្រជុំ ហើយនៅក្នុងការពិភាក្សាដោះស្រាយ ដោយឈ្មោះ [redacted] ហ៊ុយ បានអះអាងថា គោញីដែលឈ្មោះ [redacted] សុខ ចាប់នោះ គឺជារបស់គាត់ ដោយគាត់សំអាងថា គោគាត់មានសម្បុរស ក្បាលក្រហមព្រឿងៗ ហើយកំពស់នេះ គឺជាគោរបស់គាត់ហើយ រីឯឈ្មោះ [redacted] សុខ ក៏បានអះអាងថា

ជាគោរបស់គាត់ដែរ ដោយមានការជជែកគ្នា ភាគីទាំងពីរក៏បាននាំគ្នាទៅមើលគោជាក់ស្តែង ដែលចងទុកនៅផ្ទះរបស់ឈ្មោះ [redacted] ហ៊ាប ព្រោះឈ្មោះ [redacted] ហ៊ាប បានទិញពីឈ្មោះ [redacted] សុខ រួចហើយ ។ នៅពេលដែលឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហ៊ុយ ទៅមើលគោ នៅផ្ទះរបស់ឈ្មោះ [redacted] ហ៊ាប គឺខ្លួននិងលោកមេភូមិមិនបានចូលរួមនោះទេ។ លុះដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៧និង០០នាទីព្រឹក ឈ្មោះ [redacted] ហ៊ុយ បានមកប្រាប់ខ្លួនថា ពួកគាត់ដោះស្រាយគ្នាត្រូវហើយ ដោយប្រគល់គោនោះមកឱ្យខ្លួន។ ចំណែកសំណុំរឿងគេបញ្ជូនទៅដល់អធិការស្រុកហើយ។ ចំពោះឈ្មោះ [redacted] ហ៊ុយ គាត់មានគោចំនួនប្រហែលចំនួន១០ក្បាល រីឯឈ្មោះ [redacted] សុខ មានគោចំនួនប្រហែលចំនួន ៧ ទៅ៨ ក្បាល ។ កន្លងមកឈ្មោះ [redacted] សុខ មិនដែលមានរឿងរ៉ាវ ដោយសាររឿងគោជាមួយអ្នកជិតខាងនោះទេ ហើយគាត់ក៏មិនដែលបង្ករឿងអសន្តិសុខនៅក្នុងភូមិដែរ ។ ចំណែកឈ្មោះ [redacted] ហ៊ាប គឺខ្លួនស្គាល់ដែរ តែមិនច្បាស់លាស់នោះទេ ដោយដឹងត្រឹមថា គាត់មានមុខរបរជាអ្នកទិញលក់គោ និងកាប់គោលក់នៅផ្សារ ។ ខ្លួនដឹងរឿងតែប៉ុណ្ណឹងទេ។

**-ការកត់សម្គាល់ខ្លីៗ របស់ជនជាប់ចោទទាំងពីរនាក់ថា៖** (គ្មាន)

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖** ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ,អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,អំណានចម្លើយសាក្សី និង ភស្តុតាងនានា និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មានការស៊ីសង្វាក់គ្នាថាជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ លួច ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ហ៊ាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចតាមផ្លូវច្បាប់។

**-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ាប បានធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានស្តាប់អំណានចម្លើយនាពេលសវនាការ នេះរួចមកឃើញថា តាមអង្គហេតុកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ មានករណី អំពើលួច និង ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្រាកដមែន។ តែតាមការពិនិត្យភស្តុតាងនានាៗនៅក្នុងសំណុំរឿងពុំមានជាប់ពាក់ព័ន្ធជាមួយកូនក្តីខ្ញុំបាទដូចការចោទប្រកាន់នោះទេ ។ កូនក្តីខ្ញុំបាទទិញគោទៅតាមតម្លៃទីផ្សារ ដោយពុំមានការកេងតម្លៃពីបុគ្គលណាឡើយ ។ ហើយក្នុងការលក់.ទិញគោនេះគឺ កូនក្តីខ្ញុំបាទបានទិញពីអ្នកស្រុកនៅតំបន់នោះ មិនមានធ្វើលិខិតអ្វីទេសុទ្ធតែអ្នកស្គាល់គ្នាផងដែរ ។ ដូចនេះសុំឱ្យចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ លើកលែងការចោទប្រកាន់ដល់កូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះ។

**-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខ បានធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានស្តាប់អំណានចម្លើយនាពេលសវនាការនេះរួចមកឃើញថា: តាមអង្គហេតុកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០២១ មានករណី អំពើលួច និង ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្រាកដមែន។ ដោយកូនក្តីខ្ញុំបាទត្រូវបានរងការចោទប្រកាន់នៅម៉ោង៣ទៀបភ្លឺទៅវិញ ។ ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ហ៊ុយ ដែលជាម្ចាស់គោ គ្មានចម្លើយតាំងពីដំណាក់កាលចៅក្រមស៊ើបសួរ រហូតមកដល់ពេលសវនាការនេះ គឺមិនមានភាពច្បាស់លាស់ ថាក្នុងការបាត់គោនេះមិនប្រាកដជាគោរបស់ខ្លួនឡើយ . តាមចម្លើយសាក្សីមានគ្រប់គ្រាន់ ។ ហើយកូនក្តីខ្ញុំបាទមានគោនៅសល់៧ក្បាល ដោយបានលក់១ក្បាលឱ្យឈ្មោះ [redacted] ហ៊ាប បាត់ហើយ។ ដូចនេះសុំចៅក្រមក្រុមប្រឹក្សាជំនុំជម្រះមេត្តាលើកលែងការចោទប្រកាន់ដល់កូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះ។



Scanned with CamScanner

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

-ក្រោយពីបានពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

**សំអាងហេតុ**

១.តុលាការទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៧១៧ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៨០៥ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ធ្វើឡើងក្នុងកំណត់ច្បាប់ ដូច្នេះតុលាការអាចលើករឿងក្តីនេះមកជំនុំជម្រះតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ក្រោយពីបានស្តាប់អំណានចម្លើយ សួរដេញដោលនាពេលសវនាការ ទៅតាមអង្គហេតុនៅក្នុងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ របស់ចៅក្រមស៊ើបសួរ អាចបញ្ជាក់បានថា ពិតជាមានអង្គហេតុនៃអំពើ លួច ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ និងអង្គហេតុនៃអំពើ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ ប៉ោង ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ប្រាកដមែន ។

៣.តាមរបាយការណ៍សំយោគរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺលេខ ២០៣/២២ របក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជាក់ថា ពិតជាមានអំពើ លួច ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted]សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ និងអំពើ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា ៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ប្រាកដមែន ។

៤.តាមចម្លើយអំណានរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ុយ ភេទប្រុស អាយុ២៦ឆ្នាំ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីចង្វាក់គ្នាជាមួយអង្គហេតុនៅក្នុងសំណុំរឿងនេះ រួមជាមួយភស្តុតាងនានា ដែលកំណត់បានថាជនជាប់ចោទឈ្មោះ[redacted]សុខ ភេទប្រុស អាយុ៤០ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៥.តាមអំណានចម្លើយនាពេលសវនាការរបស់ជនជាប់ចោទឈ្មោះ[redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ និងឈ្មោះ [redacted] ប៊ិាប ភេទប្រុស៤២ឆ្នាំ បានឆ្លើយសារភាពនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។ ហើយរួមជាមួយរបាយការណ៍សំយោគលេខ២០៣/២២ របក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់ស្នងការនគរបាលខេត្តកំពង់ស្ពឺ , ភស្តុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿង ក៏ដូចជាចម្លើយដើមបណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីមួយចំនួន បញ្ជាក់បានថាអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខ ត្រូវបានចាត់ទុកថាជាអំពើ លួច តាមមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ អំពើ ទទួលផលចោរកម្ម តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និង



Scanned with CamScanner

មាត្រា៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ពិតប្រាកដមែន គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់ ។

៦.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ពីបទ លួច ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ប៊ាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់ ។

៧.ជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ និងឈ្មោះ [redacted] ប៊ាប ភេទប្រុស៤២ឆ្នាំ បានយល់ដឹងនូវអំពើរបស់ខ្លួនថាជាអំពើ លួច និង ទទួលផលចោរកម្ម តែជនជាប់ចោទរូបនេះ ទោះបីដឹងថាជាអំពើខុសច្បាប់យ៉ាងណាក៏ដោយ ក៏បានបង្ហាញឱ្យឃើញពីចេតនាទុច្ចរិត របស់ជនជាប់ចោទក្នុងការប្រព្រឹត្តបទល្មើសនេះដែរ។

៨.ជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ និងឈ្មោះ [redacted] ប៊ាប ភេទប្រុស៤២ឆ្នាំ គឺជានីតិជនដែលមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួននៅខណៈពេលដែលប្រព្រឹត្តបទល្មើសដែលអាចបណ្តាលឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និង សន្តិសុខសង្គម ព្រមទាំងទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលច្បាប់មានចែងឱ្យផ្តន្ទាទោសជាដាច់ខាត ។

៩.តាមអំណានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ុយ ភេទប្រុស អាយុ៣៦ឆ្នាំ តាមពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ និងកំណត់ហេតុបណ្តឹង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់អធិការនគរបាលស្រុកឱរ៉ាល់ ។ បានសំណូមពរ ជួយរកយុត្តិធម៌ និងសុំគោយកមកវិញ នោះបានទទួលគោញី១ក្បាល សម្បុរស ក្បាលសលាយក្រហម (ចំប៉ា) មិនមានខ្នុស កម្ពស់១ម៉ែត្រ គ្មានស្នែង តាមកំណត់ហេតុប្រគល់ទទួល ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ របស់អធិការនគរបាលស្រុកឱរ៉ាល់។ នោះគប្បីតុលាការមិនលើកយកមកពិនិត្យពិចារណាក្នុងការសម្រេចឡើយ ។

១០.សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការបានប្តឹងសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ពីបទ លួច ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ប៊ាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ តាមមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។ គឺមានអំណះអំណាង និងមូលដ្ឋានគ្រប់គ្រាន់សម្រាប់តុលាការពិចារណា និងសម្រេចតាមច្បាប់។

១១.មេធាវីលោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខ និង មេធាវីលោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ាប នាពេលសវនាការនេះថា: កូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ស្នើសុំឱ្យរួចផុតពីបទចោទនោះ គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច ។

១២.វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ វត្ថុចាប់យករួមមាន៖ ទូរស័ព្ទដៃម៉ាកVIVO ចំនួន១គ្រឿង ដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] សុខ នោះ គឺត្រូវបានប្រគល់ទៅឱ្យឈ្មោះ [redacted] ផាន់ណា ភេទស្រី អាយុ៣៦ឆ្នាំ តាមដីកាសម្រេចលេខ ១២៩៤៥ ចុះថ្ងៃ

ទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អនុប្រធានលេខាធិការដ្ឋាន នៃសាលាដំបូងខេត្តកំពង់ស្ពឺ រួចហើយ គប្បីតុលាការពុំលើកយកមកសម្រេចឡើយ។

## ហេតុដូច្នេះសាលាដំបូងខេត្តកំពង់ស្ពឺ

## សម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក.ឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ) ជានីតិជន ដាក់ពន្ធនាគារកំណត់ចំនួន០១ (មួយ) ឆ្នាំ និង៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ។

ពីបទ: លួច ប្រព្រឹត្តនៅភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១០៦ .១០៧ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] ប៊ិាប ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ) ជានីតិជន ដាក់ពន្ធនាគារកំណត់ចំនួន០៥ (ប្រាំ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា។

ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តចំណុចភូមិថ្មី ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ កថាខណ្ឌទី១ និងមាត្រា ៤០១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ និង មាត្រា១០៦ .១០៧ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុខ ,ឈ្មោះ [redacted] ប៊ិាប និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ុយ តែចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ និងប្រកាសនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ. ចៅក្រមសមាជិក. ចៅក្រមសមាជិក. ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ , ហត្ថលេខា និងត្រា៖ , ហត្ថលេខា និងត្រា៖ , ហត្ថលេខា និងត្រា៖

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]